**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ៖ **ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧**

ភាសា៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ៖ **សម្ងាត់**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jun-2018, 09:36
CMS/CFO: Ly Bunloung

# សាលដីកាសម្រេចលើពាក្យសុំរបស់ អោ អាន ឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល

**ផ្ញើជូន ÷**

**សហព្រះរាជអាជ្ញា ÷**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ឈ
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី÷**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ីន សូវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I- ប្រវត្តិនីតិវិធី

1. ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ក្នុងសំណុំរឿងនេះត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

2. នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់ពាក្យសុំដោយយោងតាមវិធាន ៧៦ (២) នៃវិធានផ្ទៃក្នុង ឲ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ឬជាជម្រើស ផ្អាកកិច្ចស៊ើបសួរនោះរហូតទាល់តែមេធាវីការពារក្តីអាចបើកកិច្ចស៊ើបសួរដោយខ្លួនឯង និងអាចដាក់សំណើឲ្យមានកិច្ចស៊ើបសួរនេះឡើងវិញ ("ពាក្យសុំ") [1]។

3. នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៧ ការិយាល័យរបស់ខ្ញុំបានសាកសួរសហព្រះរាជអាជ្ញាថាតើពួកគាត់មានបំណងឆ្លើយតបទៅនឹងពាក្យសុំនេះដែរឬទេ។ ជាលទ្ធផលសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា គាត់មិនមានបំណងផ្តល់ចម្លើយតបទេ[2] ហើយសហព្រះរាជអាជ្ញាជាតិក៏មិនបានឆ្លើយតបនឹងពាក្យសុំនោះដែរ។

## II- សារណា

4. មេធាវីការពារក្តីបានលើកឡើងយ៉ាងច្បាស់[3]ថាកិច្ចស៊ើបសួរទាំងមូលជួបបញ្ហាកំហុសនីតិវិធី ពោលគឺ ៖

   (១) ការបកស្រាយស្តង់ដារសម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួររបស់ ស.ច.ស និងត្រូវបានដាក់ពិន័យ ក្នុងសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ជាច្រើនដោយអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានរារាំងមិនឲ្យមេធាវីការពារក្តីចូលរួមពេញលេញក្នុងកិច្ចស៊ើបសួរនេះ នៅពេលរួមបញ្ចូលគ្នានឹងការហាមឃាត់មិនឲ្យភាគីនានាបើកកិច្ចស៊ើបសួរដោយខ្លួនឯងក្រោមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក និង

---

[1] សំណុំរឿងលេខ ០០៤/២-D350 *ពាក្យសុំឲ្យអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល* ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧។

[2] សំណុំរឿងលេខ ០០៤/២-D350/1.1 *ឧបសម្ព័ន្ធ ៖ អ៊ីម៉ែលពី Ruth Mary Hackler ផ្ញើជូន Filippo De Minicis តប ៖ តប ៖ ផ្ញើបន្តទៅ ៖ [ដាក់ដោយមេធាវីការពារក្តី អោ អាន] ឯកសារថ្មី១ ៖ សំណុំរឿងលេខ ០០៤/២ ពាក្យសុំឲ្យអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល* ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៧។

[3] ពាក្យសុំ កថាខណ្ឌ ២។

(២) ស្ថានភាពនេះបានបង្កើតជាវិសមភាពមធ្យោបាយតទល់ក្តី ព្រោះព្រះរាជអាជ្ញា តាមការចោទរបស់មេធាវីការពារក្តី គឺ អាចបើកកិច្ចស៊ើបសួរបឋម និងនៅតែបើកកិច្ចស៊ើបសួរដោយខ្លួនឯង សូម្បីតែនៅក្រោយពេលដែលសំណុំរឿងនោះត្រូវបានបញ្ជូនទៅឲ្យ ស.ច.ស ធ្វើកិច្ចស៊ើបសួរក្តី។

5. មេធាវីការពារក្តីយល់ថា ស្តង់ដារដែល ស.ច.ស និង អ.ប.ជ យកមកអនុវត្តលើសំណើសុំបំពេញកិច្ចស៊ើបសួរ និងការហាមឃាត់មិនឲ្យបើកកិច្ចស៊ើបសួរដោយភាគីពាក់ព័ន្ធ ជា*ការអនុវត្តហួសពីសមត្ថកិច្ច (ultra vires)* ប្រសិនបើត្រូវបានពិចារណាដាច់ដោយឡែកពីគ្នា ប៉ុន្តែលើកឡើងថា ផលប៉ះពាល់នៃចំណុចទាំងពីរនេះ នឹងរារាំងមិនឲ្យមេធាវីការពារក្តីចូលរួមបានពេញលេញ[4]។

6. មេធាវីការពារក្តីបញ្ជាក់ថា ពាក្យសុំនេះអាចធ្វើឡើងបានតែនៅពេលនេះប៉ុណ្ណោះ ព្រោះពួកគេត្រូវរង់ចាំរហូតដល់ អ.ប.ជ ចេញសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ចុងក្រោយពាក់ព័ន្ធនឹងសំណើសុំទី ១០ ឲ្យមានកិច្ចស៊ើបសួរ ដែលបានធ្វើឡើងតែនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៧ ប៉ុណ្ណោះ[5]។

## III- ពិភាក្សា

7. ពាក្យសុំនេះគ្មានមូលដ្ឋានសំអាងឡើយ។

8. មេធាវីការពារក្តីមិនបានកំណត់រកកំហុសនីតិវិធីពាក់ព័ន្ធនឹងកិច្ចស៊ើបសួរណាមួយ ឬពាក់ព័ន្ធនឹងផ្នែកមួយនៃកិច្ចដំណើរការនីតិវិធីដោយយោងតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុងនោះទេ។ បណ្តឹងតវ៉ាពិតប្រាកដរបស់មេធាវីការពារក្តី មានលក្ខណៈទូទៅ និងពាក់ព័ន្ធនឹងទំនាក់ទំនងរវាងមុខព្រួញពីរនៃក្របខណ្ឌច្បាប់ អ.វ.ត.ក ពោលគឺស្តង់ដារសម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរ និងការហាមឃាត់មិនឲ្យភាគីនានាបើកកិច្ចស៊ើបសួរដោយខ្លួនឯង។ ដូច្នេះ មានន័យថា មេធាវីការពារក្តីកំពុងប្រឆាំងនឹងទស្សនៈផ្លូវច្បាប់របស់ ស.ច.ស និង អ.ប.ជ ដែលបានបកស្រាយក្របខណ្ឌច្បាប់នេះ។ មេធាវីការពារក្តីបានស្នើឲ្យ អ.ប.ជ ពិចារណាឡើងវិញចំពោះការយល់ឃើញរបស់ខ្លួនស្តីពីច្បាប់នេះ ដោយលើកឡើងជាថ្មីនូវចំណុចដែលត្រូវបានច្រានចោលក្នុងបណ្តឹងឧទ្ធរណ៍ពីមុន។ ដូច្នេះ ពាក្យសុំនេះគឺជាហេតុផលពិតប្រាកដនៃការពិចារណាឡើងវិញលើចំណុចនានាក្នុងអង្គច្បាប់។

---

[4] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣។

[5] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤។

9. ការយោងតាមដែលលើកឡើងក្នុងពាក្យសុំនេះ ដោយផ្អែកតាមសាលដីកាសម្រេចពីមុនរបស់ អ.ប.ជ ក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹង "*ការធ្វើមោឃភាពរាល់កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះ*"[6] គឺជាការយល់ខុស។ ការដកស្រង់ចេញពីសាលដីកាសម្រេចក្នុងពាក្យសុំនេះ បានលុបចោលប្រយោគដ៏សំខាន់មួយ ខណៈដែលខ្លឹមសារពេញលេញនៃកថាខណ្ឌ ២៤ ក្នុងសាលដីកាសម្រេចរបស់ អ.ប.ជ គឺ ៖

> *អង្គបុរេជំនុំជម្រះយល់ឃើញថា នីតិវិធីធ្វើមោឃភាពដូចបានអនុវត្តនៅក្នុងសាលដីកាសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា "គឺមិនមែនតាក់តែងដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរជាទូទៅនោះទេ [...] ប៉ុន្តែត្រូវបានរៀបរៀងឡើងដើម្បីធ្វើមោឃភាពផ្នែកទាំងឡាយណានៃដំណើរការនីតិវិធី ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ ដែលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់។* ហេតុដូច្នេះ ការអនុវត្តការធ្វើមោឃភាពត្រូវតែបញ្ជាក់ហេតុផលឱ្យបានជាក់លាក់ថាតើកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះណាមួយដែលមានកំហុសនីតិវិធី និងនៅពេលដែលអាចអនុវត្តបាន បញ្ជាក់អះអាងពីផលប្រយោជន៍ដែលត្រូវបានប៉ះពាល់។ នៅក្នុងស្ថានភាពចុងក្រោយនេះ ប្រសិនបើការធ្វើមោឃភាពរាល់កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះត្រូវបានស្នើឡើង នោះអ្នកដាក់ពាក្យសុំ ត្រូវបង្ហាញពីអត្ថិភាពនៃកំហុសនីតិវិធីដែលបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ខ្លួននៅក្នុងករណីនេះទាំងមូល។ នៅពេលដែលការរំលោភសិទ្ធិរបស់ជនត្រូវចោទនៅក្រោមកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬវិធានផ្ទៃក្នុងត្រូវបានបង្ហាញឡើង កំហុសនីតិវិធីបង្កការប៉ះពាល់ដល់ផលប្រយោជន៍ នឹងនាំឱ្យឈានដល់ការធ្វើមោឃភាពកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះជាក់លាក់ បើទោះបីជាអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិលើកឡើងពីផលវិបាកនៃការធ្វើមោឃភាពទៅលើករណីនេះទាំងស្រុងក៏ដោយ[7] (សេចក្ដីបញ្ជាក់បន្ថែម)។

10. ការលើកឡើងថា ចំណុចនេះអាចលើកឡើងតែនៅពេលមានសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ចុងក្រោយ គឺមិនអាចជឿជាក់បានឡើយ ព្រោះមេធាវីការពារក្ដីបានបញ្ជាក់ដោយផ្ទាល់ថា ពួកគេបានទាញចំណាប់អារម្មណ៍របស់ អ.ប.ជ ម្ដងហើយម្ដងទៀតឱ្យផ្ដោតលើអង្គសេចក្ដីក្នុងដំណើរការបណ្ដឹងឧទ្ធរណ៍[8]។ ដូច្នេះ មេធាវីការពារក្ដីបានលើកឡើងរួចមកហើយនូវបញ្ហាសំខាន់ដែលពួកគេអះអាងនៅពេលបច្ចុប្បន្នថា មិនអាចលើកឡើងបានកាលពីមុន។ អ.ប.ជ មិនយល់ស្របនឹងការលើកឡើងនៅពេលបន្ទាប់នោះឡើយ ទោះបីជាមានឱកាសជាច្រើនក្នុងការផ្លាស់ប្ដូរ

---

[6] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៧។

[7] សំណុំរឿងលេខ ០០២/-D263/2/6 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1)* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ២៤។ បណ្ដឹងឧទ្ធរណ៍នេះមិនទទួលបានជោគជ័យឡើយ។

[8] ពាក្យសុំ កថាខណ្ឌ ៣០ ចច។

ការយល់ឃើញរបស់ខ្លួនក្តី។ លើសពីនេះ គ្មានអ្វីអាចរារាំងមេធាវីការពារក្តីមិនឲ្យដាក់ញត្តិសុំឲ្យមានការពិចារណាឡើងវិញនៅពេលដែល អ.ប.ជ អនុញ្ញាតឲ្យប្រើប្រាស់ស្តង់ដារដែលអនុវត្តដោយ ស.ច.ស និងការហាមឃាត់ភាគីមិនឲ្យធ្វើបើកកិច្ចស៊ើបសួរនោះទេ។ ឥទ្ធិពលដែលអាចកើតចេញពីការរួមបញ្ចូលចំណុចទាំងពីរនេះ ត្រូវបានទទួលស្គាល់ជាគោលការណ៍។

11. ការលើកឡើងរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងវិសមភាពមធ្យោបាយតទល់ក្តី ដែលរងការចោទប្រកាន់ ដោយសារសមត្ថភាពរបស់ព្រះរាជអាជ្ញាក្នុងការបើកកិច្ចស៊ើបសួរដោយខ្លួនឯងនៅដំណាក់កាលបឋម និងក្រោយពេលដែលសំណុំរឿងនេះត្រូវបានបញ្ជូនទៅ ស.ច.ស ក្រោមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ត្រូវបានដោះស្រាយដោយផ្អែកតាមភាពស៊ីជម្រៅចាំបាច់ក្នុងសំណុំរឿង ០០៣ កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦[9]។ សាលដីកាសម្រេចនេះត្រូវបានដាក់ក្នុងសំណុំរឿង ០០៤ នៅពេលនោះ ប៉ុន្តែមិនត្រូវបានដកស្រង់ដោយមេធាវីការពារក្តីក្នុងពាក្យសុំនេះឡើយ។ ដូច្នេះមិនចាំបាច់បន្ថែមចំណុចអ្វីផ្សេងទៀតឡើយ។

12. ពាក្យសុំនេះត្រូវបានដាក់នៅក្រៅវិសាលភាពថិរវេលា ក្រោមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ក្រោយការជូនដំណឹងលើកទី ១ អំពីការបិទកិច្ចស៊ើបសួរ[10] និងសូម្បីតែក្រោយការជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរក្នុងសំណុំរឿងនេះ ដែលបានផាត់ចេញនូវការដាក់ឯកសារបន្ថែមទៀតដោយភាគីពាក់ព័ន្ធក្រោមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង[11]។ ដោយសារតែយើងនឹងបដិសេធពាក្យសុំនេះដោយផ្អែកលើអង្គសេចក្តី និងគ្មានការណែនាំជាមុនពី អ.ប.ជ ស្តីពីបញ្ហានេះ យើងមិនយល់ថាចាំបាច់ត្រូវមានសំអាងហេតុក្នុងកាលៈទេសៈនេះ ថាតើពាក្យសុំនេះស្ថិតនៅក្រៅវិសាលភាពថិរវេលា ឬយ៉ាងណាឡើយ។

13. ដោយសារតែមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូលកំពុងខ្វះខាតជាក់ស្តែងរួចទៅហើយ គ្មានមូលដ្ឋាន ឬភាពចាំបាច់ក្នុងការពិចារណាពីសំណូមពរជាជម្រើសឡើយ (ឧ. ការចេញដីកាឲ្យផ្អាកដំណើរការកិច្ចនីតិវិធី)។

---

[9] សំណុំរឿងលេខ ០០៤-D308 *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតចុះពិនិត្យដល់ទីតាំង* ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ១៤។

[10] សំណុំរឿងលេខ ០០៤/២-D334 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ៣ និង ៦។

[11] សំណុំរឿងលេខ ០០៤/២-D334/2 *សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ កថាខណ្ឌ ១២-១៦ និង ១៨។

14. ដើម្បីធានាតម្លាភាព យើងសូមជូនដំណឹងដល់ភាគីពាក់ព័ន្ធថា យើងយល់ឃើញថា បណ្តឹងឧទ្ធរណ៍ណាមួយ ដែលអាចត្រូវបានដាក់ប្រឆាំងនឹងសាលដីកាសម្រេចនេះ មិនរារាំង ស.ច.ស មិនឲ្យបញ្ជូនបន្តសំណុំរឿងនេះទៅសហព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានស្ថាពរនោះទេ។ បណ្តឹងឧទ្ធរណ៍បែបនេះមិនត្រូវបានគ្របដណ្តប់ដោយការហាមឃាត់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ដែលមិនទាន់ជំនុំជម្រះ ក្រោមវិធាន ៧៦ (៤) នៃវិធានផ្ទៃក្នុងឡើយ ហើយវាក៏មិនចាំបាច់ផងដែរ ក្នុងការរង់ចាំឲ្យមានសំអាងហេតុជាក់ស្តែងនៃភាពយុត្តិធម៌ផ្នែកនីតិវិធី និងភាពឆឿនរហ័សនោះដែរ។ ប្រសិនបើ អ.ប.ជ សម្រេចធ្វើមោឃភាពកិច្ចស៊ើបសួរទាំងស្រុងរបស់ខ្លួន ផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធី នឹងមានលក្ខណៈធ្ងន់ធ្ងរ ហើយភាគីនានា គួរត្រូវបានជូនដំណឹងភ្លាមៗថានឹងមិនតម្រូវឲ្យមានដីកាសន្និដ្ឋានស្ថាពរបន្ថែមនោះទេ។ ផ្អែកតាមប្រវត្តិនីតិវិធីដែលលើកឡើងខាងលើ ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ជាច្រើន យើងយល់ថា គ្មានលទ្ធភាពជាក់លាក់នៃការកើតមានបញ្ហាដូច្នោះឡើយ ហើយមិនចាំបាច់បញ្ឈប់កិច្ចដំណើរការនីតិវិធីដោយផ្អែកលើភាពស្រពិចស្រពិលថា បណ្តឹងឧទ្ធរណ៍មួយអាចទទួលបានជោគជ័យនោះទេ។ ចំណុចនេះក៏អនុវត្ត*ដូចគ្នា*ចំពោះហានិភ័យនៃដីកាផ្អាកកិច្ចដំណើរការនីតិវិធីរបស់ អ.ប.ជ ផងដែរ។

15. ចុងបញ្ចប់ យើងយល់ថា សាលដីកាសម្រេចនេះបម្រើឲ្យផលប្រយោជន៍របស់ភាគីពាក់ព័ន្ធក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយយើងនឹងបង្គាប់ឲ្យក្រឡាបញ្ជី ដាក់សាលដីកាសម្រេចនេះក្នុងសំណុំរឿងទាំងនោះ។

**តាមសំអាងហេតុខាងលើ យើងសម្រេច ៖**

16. **បដិសេធ**ពាក្យសុំនេះ។

17. **ជូនដំណឹង**ដល់ភាគីពាក់ព័ន្ធថា រាល់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលដីកាសម្រេចនេះនឹងមិនពន្យារពេលសំណុំរឿងដែលកំពុងត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា រួមទាំងលក្ខណៈវិនិច្ឆ័យទាំងអស់ផ្សេងទៀតក្រោមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុងដែលកំពុងត្រូវអនុវត្តតាមឡើយ និង

18. **បង្គាប់ឲ្យ** ក្រឡាបញ្ជី ដាក់សាលដីកាសម្រេចនេះក្នុងសំណុំរឿង ០០៣ និង ០០៤។

សាលដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ចំណែកសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់នៅពេលក្រោយ។

ភ្នំពេញ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧

ចៅក្រម **Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**